# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសអ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-July-2016, 14:07
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសម្ងាត់មួយ** ១

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## ការដាក់បន្ថាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពីសំណុំរឿង០០៣ និង០០៤ ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**

លោកស្រី ទូច វលក្ស

លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

## I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“សហព្រះរាជអាជ្ញា”) សូមដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤ ពីសំណុំរឿង០០៣ និង/ឬ០០៤ ទៅក្នុងសំណុំរឿង០០២ ដែលបំពេញតាមកាតព្វកិច្ចនៃការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា(“សម្ភារៈ”)។ សម្ភារៈទាំងអស់នេះសុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធសម្ងាត់បំផុតមួយគឺ: **ឧបសម្ព័ន្ធ ក**។

2. សហព្រះរាជអាជ្ញា សូមស្នើការអនុញ្ញាតដាក់បង្ហាញសម្ភារៈទាំងនេះ ដែលបានបញ្ចូលនៅក្នុងសំណើសុំដាក់បង្ហាញនេះ តាមរយៈសំណើពីរ (សំណើទាំងពីររួមគ្នាហៅថា “សំណើ”) ជូនសហចៅក្រមស៊ើបអង្កេត (“សចស”) នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥[1]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“សចសអ”) បានផ្តល់ការអនុញ្ញាតឲ្យដាក់បង្ហាញសំណើនេះ ទាក់ទងនឹងឯកសារដែលបច្ចុប្បន្នបាននឹងកំពុងដាក់បង្ហាញនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥[2] និងទី២៨ ខែមករា ឆ្នាំ២០១៦[3] (“សេចក្តីសម្រេចរបស់ សចសអ”)។ សេចក្តីសម្រេចទាំងនោះ ត្រូវបានចែកជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញ។

3. សហព្រះរាជអាជ្ញា បានកត់សម្គាល់ទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០២/០២ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥[4]។ អង្គជំនុំជម្រះសាលាដំបូងបាន

---

[1] សំណុំរឿង០០៣-**D100/14** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍ផ្នែកគាំពារជនរងគ្រោះ, ១៣ សីហា ២០១៥។ សំណុំរឿង០០៤-**D193/38** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍អង្គភាពគាំពារជនរងគ្រោះនៃសំណុំរឿងលេខ០០៤ ទៅក្នុងសំណុំរឿងលេខ០០២, ១៣ សីហា ២០១៥។

[2] សំណុំរឿង០០៤-**D193/61** ដីកាសម្រេចលើសំណើ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ, ១៧ ធ្នូ ២០១៥ (“សេចក្តីសម្រេច”)។

[3] សំណុំរឿង០០៣-**D100/17** ដីកាសម្រេចលើសំណើ D100, D100/2, D100/10, D100/13, D100/14 និង D100/16 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ, ២៨ មករា ២០១៦។

[4] **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ២២ តុលា ២០១៥។

បង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនអង្គជំនុំជម្រះ និងភាគី នូវឯកសារដោះបន្ទុកពីសំណុំរឿង០០៣ និង០០៤ ទៅតាមមូលដ្ឋានមួយដែលត្រូវធ្វើជាបន្តបន្ទាប់ រហូតដល់ពេលបញ្ចប់សំណុំរឿង០០២/០២[5]។ អង្គជំនុំជម្រះក៏បានបង្គាប់ផងដែរឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញគ្រប់កំណត់ហេតុរបស់បុគ្គលម្នាក់ៗទាំងអស់នៃសំណុំរឿង០០៣ និង០០៤ ដែលបានស្នើឱ្យមកបំភ្លឺនៅក្នុងសំណុំរឿង០០២/០២[6]។ អង្គជំនុំជម្រះក៏បានធ្វើការសម្រេចបន្ថែមថា សម្ភារៈបន្ថែមណាមួយនៃសំណុំរឿង០០៣ និង០០៤ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់ជូនស្របតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង គួរត្រូវបានដាក់ក្នុងពេលវេលានៃការដាក់ពាក្យសុំដែលមានសម្អាងហេតុ អនុលោមតាមវិធាន៨៧(៤)[7]។

4. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់លើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ លើសំណើរបស់ នួន ជា ទាក់ទងនឹងកាតព្វកិច្ចនៃការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០២/០១[8]។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនអង្គជំនុំជម្រះតុលាការកំពូល និងគូភាគី នូវភ័ស្តុតាងថាតើ (i) បានផ្ដល់ជូនដោយសាក្សីដែលបានធ្វើការដោយផ្ទាល់ជាមួយ រស់ ញឹម ឬ (ii) ពាក់ព័ន្ធនឹងការប្រឆាំងនឹង ប៉ុល ពត និង នួន ជា នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

5. សហព្រះរាជអាជ្ញាបានកំណត់អាទិភាពលើការពិនិត្យឡើងវិញ ទាំងការអនុញ្ញាត និងកំណត់ហេតុថ្មីនៃការស្ដាប់ចម្លើយសាក្សី និងទាំងរបាយការណ៍នៃសកម្មភាពការស៊ើបអង្កេត សម្រាប់ការដាក់បង្ហាញ នៅមុនការពិនិត្យឡើងវិញនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំង ៤៥៨ នៃសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញនៅក្នុងសេចក្ដី សម្រេចរបស់ សចសអ ប្រឆាំងនឹងលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលបានដាក់ជាគោលដោយ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ហើយដោយបានពិនិត្យមើល ដើម្បីធានាថា អ្នកដាក់ពាក្យសុំម្នាក់ៗមិនបាននៅក្នុងសំណុំរឿង០០២ តាមទម្រង់មួយផ្សេងទៀតនោះទេ។ សហព្រះរាជ

---

5 *ដដែលដូចខាងលើ,* កថាខណ្ឌ២១-២៤, សេចក្ដីសម្រេចបញ្ចប់, EN 01157631-33, 01157640-41។

6 *ដដែលដូចខាងលើ,* កថាខណ្ឌ២៥-២៧, សេចក្ដីសម្រេចបញ្ចប់, EN 01157634-35, 01157640-41។

7 *ដដែលដូចខាងលើ,* កថាខណ្ឌ២៨-៣០, សេចក្ដីសម្រេចបញ្ចប់, EN 01157635-36, 01157640-41។

8 **F2/4/2** សេចក្ដីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភ័ស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២/០១, ១៦ មីនា ២០១៥, សេចក្ដីសម្រេចបញ្ចប់។

អាជ្ញា ពីពេលមុន បានដាក់បង្ហាញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ ដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុងសេចក្តីសម្រេចរបស់ សចសអ ដែលជាសេចក្តីថ្លែងរបស់បុគ្គលដែលត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្ម[9]។ សហព្រះរាជអាជ្ញា នៅទីនេះ ដាក់បង្ហាញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ ដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុងសេចក្តីសម្រេចនានា ដែលមានផ្ទុកទៅដោយសម្ភារៈដោះបន្ទុកជាក្តានុពល។

6. អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ដល់សហព្រះរាជអាជ្ញាថា ជាដំបូង ត្រូវដាក់ពាក្យស្នើសុំការដាក់បង្ហាញ ជូនទៅអង្គជំនុំជម្រះនេះឲ្យទទួលយកនូវភស្តុតាងដែលសហព្រះរាជអាជ្ញាស្វែងរកធ្វើការដាក់បង្ហាញជាមុនសិន ហើយបន្ទាប់មក ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យទទួលយកនូវឯកសារណាមួយដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ[10]។

7. អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានបង្គាប់ពីមុនថា រាល់ការដាក់បង្ហាញឯកសារទាំងអស់ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្ន ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះ ថាតើគប្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[11]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីឯកសារដែលមាននៅក្នុង **ឧបសម្ព័ន្ធ ក** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

8. ការផ្តល់សិទ្ធិឲ្យដាក់បង្ហាញសម្ភារៈក្នុងឧសម្ពន្ធ **ក** គឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវមួយចំនួនខាងក្រោម ដែលកំណត់ដោយ សចសអ ដូចតទៅ៖[12]

---

[9] **E319/45** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុនៃសកម្មភាពស៊ើបសួរទៅក្នុងសំណុំរឿង០០២, ២១ មេសា ២០១៦។

[10] **E127/7/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ព័ត៌មានទាក់ទងកំណត់ហេតុស្តាប់ចម្លើយសាក្សីសំណុំរឿង០០៣ និង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[11] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ឆ្នាំ២០១២, ទំព័រ១។

[12] សំណុំរឿង០០៤-**D193/61** ដីកាសម្រេចលើសំណើ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ, ១៧ ធ្នូ ២០១៥,

ក. សម្ភារៈទាំងអស់ត្រូវចាត់ទុកជាការសម្ងាត់។

ខ. ក្នុងករណីដែលសម្ភារៈទាំងឡាយត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ ត្រូវចាត់ទុកជាការសម្ងាត់។

គ. សម្ភារៈទាំងនោះមិនត្រូវផ្សព្វផ្សាយឲ្យលើសពីបុគ្គលទាំងឡាយដែលបានកំណត់អត្តសញ្ញាណជាក់ច្បាស់នៅក្នុងលក្ខខណ្ឌតម្រូវនានាដែលមានចែងនៅក្នុងនោះទេ។

ឃ. ក្នុងករណីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសាររបស់ខ្លួនត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញក្នុង **ឧបសម្ព័ន្ធ ក** ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មនោះ ពួកគេអាចធ្វើដូច្នេះបានក្នុងសវនាការបើកចំហរ ប្រសិនបើឈ្មោះរបស់ពួកគេ និងព័ត៌មានកំណត់អត្តសញ្ញាណផ្សេងទៀតត្រូវបានរក្សាជាការម្ងាត់ ហើយពួកគេត្រូវបានកំណត់អត្តសញ្ញាណតែតាមរយៈរហស្សនាម ដែលបានកំណត់ឲ្យសម្រាប់សំណុំរឿង០០២/០២ តែប៉ុណ្ណោះ។

ង. សម្ភារៈដែលបានផ្តល់ជូនអនុលោមតាម **ឧបសម្ព័ន្ធ ក** មិនត្រូវផ្សព្វផ្សាយទៅកាន់សាធារណៈជនក្នុងទម្រង់ណាមួយ ឬតាមរយៈមធ្យោបាយសារព័ត៌មានបែបណាក៏ដោយ ដែលលើសពីភ័ស្តុតាងដែលបានបង្ហាញក្នុងសវនាការបើកចំហរបស់តុលាការឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារនានាដែលបានដាក់បង្ហាញក្នុង **ឧបសម្ព័ន្ធ ក** ត្រូវកំណត់អត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែដោយរហស្សនាមដែលបានដាក់ឲ្យសម្រាប់សំណុំរឿង០០២/០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

---

កថាខណ្ឌ ៣២។ សំណុំរឿង០០៣-**D100/17** ដីកាសម្រេចលើសំណើ D100, D100/2, D100/10, D100/13, D100/14, និង D100/16 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ, ២៨ មករា ២០១៦។ សេចក្តីសម្រេច, កថាខណ្ឌ ១៨។

ឆ. សម្ភារៈទាំងនោះត្រូវផ្តល់ជូនទៅមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីររូប មេធាវីប្រចាំការរបស់ ខៀវ សំផន ("មេធាវីប្រចាំការ") និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិកត្រូនិច។

ជ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់បង្ហាញសម្ភារៈឲ្យទៅតែសមាជិកនៃក្រុមការងាររបស់ខ្លួន ដែលទទួលបានការងារជាផ្លូវការ តាមវិធាន ២២(៥) និង វិធាន ១២ *ស្ទួនពីរ* (៤) នៃវិធានផ្ទៃក្នុង និងកម្មសិក្សាការីដែលត្រូវបានចាត់តាំងជាផ្លូវការប៉ុណ្ណោះ។

ឈ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើមដែលពួកគេបានទទួលឡើយ ក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៃឯកសារនោះដោយសមាជិកនៃក្រុមនានារបស់ខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះប៉ុណ្ណោះ។

ញ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនអនុលោមតាមសេចក្តីសម្រេចនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះជូន សចស វិញ។

ឋ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចស។

## II. **ដំណោះស្រាយដែលស្នើឡើង**

9. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ក**៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ | **លោក** **Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |